**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីព្យាបាលជាសះស្បើយ ០៦នាក់
## ករណីវិជ្ជមានកូវីដ-១៩ ថ្មី ០១នាក់ និងករណីលាប់ជំងឺកូវីដ-១៩ ឡើងវិញ ០១នាក់
## នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖**

ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មាន៖

– អ្នកព្យាបាលជាសះស្បើយ សរុបចំនួនកើនដល់ ៦៨នាក់ (ស្មើនឹង ៥៧,៦៣% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០៣នាក់ បុរសជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិបែលហ្ស៊ិក ០១នាក់ បុរសជនជាតិបារាំង ១២នាក់ (ក្នុងនេះមានទារកអាយុ ០៤ខែ) ស្ត្រីជនជាតិបារាំង ១២នាក់ បុរសជនជាតិម៉ាឡេស៊ី ០៧នាក់ បុរសជនជាតិខ្មែរ ២៧នាក់ និងស្ត្រីជនជាតិខ្មែរ ០៤នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)។

– អ្នកដែលកំពុងសម្រាកព្យាបាល សរុបចំនួន ៥០នាក់ (ស្ត្រី ១៦នាក់ និងបុរស ៣៤នាក់) នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត

– អ្នកមានវីរុសកូវីដ-១៩ ដែលបានរកឃើញទាំងអស់ (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន ១១៨នាក់ (ស្ត្រី ៣៥នាក់ និងបុរស ៨៣នាក់)។

**២. ករណីជាសះស្បើយ៖** មាន ០៦នាក់

- ស្ត្រីជនជាតិអង់គ្លេសអាយុ ៧៩ឆ្នាំ ជាអ្នកដំណើរនាវា Wiking Cruise Journey សំចតនៅខេត្តកំពង់ចាម ដែលត្រូវបានយកមកសម្រាកព្យាបាលនៅមន្ទីរពេទ្យក្នុងរាជធានីភ្នំពេញ បានជាសះស្បើយ ដោយទទួលលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យ ដើម្បីវិលត្រឡប់ទៅប្រទេសអង់គ្លេសវិញ។

- បុរសជនជាតិបារាំងចំនួន ០២នាក់៖ មានអាយុ ៦២ឆ្នាំ និងអាយុ ៦៣ឆ្នាំ ជាអ្នកទេសចរបារាំងនៅខេត្តព្រះសីហនុ បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ០២លើក និងស្នាក់នៅក្នុងបន្ទប់ដោយឡែកនៃសណ្ឋាគារក្នុងក្រុងព្រះសីហនុ ដើម្បីរង់ចាំជើងហោះហើរវិលត្រឡប់ទៅប្រទេសបារាំងវិញ។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) [illegible] / [illegible] ៥០៩

- ស្ត្រីជនជាតិបារាំង ០៣នាក់ ៖ មានអាយុ ៦៣ឆ្នាំ អាយុ ៥៩ឆ្នាំ និងអាយុ ៦៧ឆ្នាំ ជាភ្ញៀវទេសចរបារាំង ដែលបានសម្រាកព្យាបាលនៅបន្ទប់ដោយឡែកនៃសណ្ឋាគារក្នុងក្រុងព្រះសីហនុ បានជាសះស្បើយដោយទទួលលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ចំនួន២លើក និងត្រូវវិលត្រឡប់ទៅប្រទេសបារាំងវិញ។

**៣. ករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖** ០១នាក់

- ស្ត្រីជនជាតិចិន អាយុ ៣០ឆ្នាំ ជាភ្ញៀវទេសចរ និងចង់រកស៊ីបើកហាងនៅកម្ពុជា ស្នាក់នៅបណ្តោះអាសន្ន នៅរាជធានីភ្នំពេញ ជាករណីប៉ះពាល់ផ្ទាល់ជាមួយគូសង្សារ (បុរសជនជាតិចិនមានវីរុសកូវីដ-១៩ រកឃើញនៅប្រទេសចិន និងស្ត្រីជនជាតិវៀតណាមមានវីរុសកូវីដ-១៩ រកឃើញនៅកម្ពុជា) ត្រូវបានរកឃើញវិជ្ជមានវីរុសកូវីដ-១៩ ហើយត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

**៤. ករណីលាប់ជំងឺកូវីដ-១៩ ឡើងវិញ ៖** ០១នាក់

- បុរសខ្មែរ អាយុ ៥០ឆ្នាំ រស់នៅសង្កាត់ច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយទទួលបានលទ្ធផលតេស្តវិជ្ជមានវីរុសកូវីដ-១៩ ដែលគាត់បានលាប់ជំងឺនេះម្តងទៀតបន្ទាប់ពីធ្វើតេស្តក្រោយពេលគាត់ជាសះស្បើយបាន ១៥ថ្ងៃរួចមក ហើយត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃព្រហស្បតិ៍ ២រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩